ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

---

តុលាការខេត្តកំពង់ធំ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៧១ ចុះថ្ងៃទី ១១

ខែ កុម្ភៈ ឆ្នាំ ២០០៥

សាលក្រមព្រហ្មទណ្ឌ

លេខ ៤៧ គ ចុះថ្ងៃទី ២៤

ខែ មិថុនា ឆ្នាំ ២០០៥

---

## គាមនាមប្រជារាស្ត្រខ្មែរ

## តុលាការខេត្តកំពង់ធំ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈ នៅសាលជំនុំជំរះតុលាការខេត្តកំពង់ធំ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០៥ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោកស្រី [redacted] អនុប្រធានតុលាការខេត្តកំពង់ធំ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្តកំពង់ធំ

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីតុលាការខេត្តកំពង់ធំ

-ដើម្បីជំនុំជំរះឈ្មោះ គ រ ភេទប្រុស អាយុ ៣៦ឆ្នាំ ជាតិខ្មែរ កើតនៅភូមិត្នោត ឃុំកំពង់ចិនជើង ស្រុកស្ទោង ខេត្តកំពង់ធំ ទីលំនៅសព្វថ្ងៃ នៅភូមិកំពង់រទេះ ឃុំកំពង់រទេះ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ សាសនាព្រះពុទ្ធ របររកស៊ីធ្វើស្រែ ប្រពន្ធឈ្មោះ ម ផ (រ) មានកូន ០៥នាក់ ឪពុកឈ្មោះ ន គ (រ) ម្តាយឈ្មោះ ឱ ន (ស) ទោសពីមុនគ្មាន ។

ពីបទ : **ជេរប្រមាថ** ប្រព្រឹត្តនៅភូមិកំពង់រទេះ ឃុំកំពង់រទេះ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៤ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ អ ព ភេទស្រី អាយុ ៥៤ឆ្នាំ នៅភូមិកំពង់រទេះ ឃុំកំពង់រទេះ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ។

ប្តឹងថា : កាលពីថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៤ វេលាម៉ោង ១២:៣០នាទីយប់ ឈ្មោះ គ រ បានស្រវឹងស្រាហើយជេរប្រមាថខ្ញុំទៀត មីចោរកញ្ជុយ មានក្តយប៉ុន្មាននាក់ឱ្យគេចុយ មីចោកបានពុះទ្រូងយកប្រម៉ាត់ត្រាំស្រាក្លែម សូមទាមទារជម្ងឺចិត្ត ០២លានរៀល ។

-ដីកាសន្និដ្ឋានស្ថាពរលេខ ១១៦ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៥ របស់ព្រះរាជអាជ្ញាអមតុលាការខេត្តកំពង់ធំ ។

-ដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ២១០ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៥ របស់ប្រធានតុលាការខេត្តកំពង់ធំ ។

សាលក្រមនេះបានចូលជាស្ថាពរកាលពីថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៥រួចហើយ ដោយគ្មានភាគីណាមួយបានប្តឹងតវ៉ាតាមការកំណត់ច្បាប់ ។

កំពង់ធំ, ថ្ងៃទី ៣០ ខែ ៨ ឆ្នាំ ២០០៥

ចៅក្រមជំនុំជំរះ

[redacted]



Scanned with CamScanner

កាលពីថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៤ វេលាម៉ោង ១២:៣០នាទីយប់ ឈ្មោះ អ ព ដេកនៅលើផ្ទះ ស្រាប់តែឈ្មោះ គ រ ស្រែកជេរថា មីកាព្រិន ង៉ែងមានក្បួយប៉ុន្មាននាក់ទៀតសម្រាប់ដើរឱ្យគេចុយ មីចោកទាប មីពូជចោក បានតែពុះទ្រូងយកធ្វើមក្លែមស្រា ។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ គ រ បានឆ្លើយបញ្ជាក់ថា :កាលពីថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៤ វេលាម៉ោង ៩:០០យប់ ខ្ញុំចេញពីផឹកស៊ី ពីផ្ទះឈ្មោះ អ នៅភូមិកំពង់រទេះ មកផ្ទះមានការឈ្លោះជាមួយប្រពន្ធបន្តិចបន្តួច ។ ខ្ញុំមិនបានជេរទៅលើឈ្មោះ អ ព តែពេលនោះខ្ញុំស្រវឹងផងដោយមិនចាំអ្វីទេ ។ សូមតុលាការជួយរកយុត្តិធម៌ឱ្យផង ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ អ ព បានឆ្លើយបញ្ជាក់ថា : កាលពីថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៤ វេលាម៉ោង ១២:៣០នាទីយប់ ខ្ញុំដេកនៅលើផ្ទះ ឈ្មោះ គ រ បានស្រែកជេរមកលើខ្ញុំថា មីការ ព ង៉ែងមានក្បួយប៉ុន្មាននាក់សម្រាប់ដើរឱ្យគេចុយ មីចោកទាប បានតែពុះទ្រូងយកធ្វើមក្លែមស្រា ខ្ញុំមិនបានជេរតបទៅវិញទេ ។ សុំឱ្យទាមទារជម្ងឺចិត្ត ២.០០០.០០០រៀល ។

-សាក្សីបំភ្លឺឈ្មោះ ម សរ បានឆ្លើយបញ្ជាក់ថា : ឈ្មោះ គ រ ផឹកស្រាស្រវឹងមកដល់ផ្ទះជេរបញ្ចោរ ជៀមជាមដល់អ្នកជិតខាង និងប្រពន្ធកូនស្ទើរតែរាល់យប់ ។ យប់ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៤ ម៉ោង ១១:៣០ នាទី ជេរ ៩ ឆ អាចុយម្ដាយ ចេញមកកាប់គ្នាអា ឆ ធ្វើសាក្សីឱ្យយាយ ឡ ។ រហូតម៉ោង ១២:០០យប់ ឈ្មោះ គ រ ជេរមកលើ ខ ឡ សុំសីលមិនដឹងមុខ ធ្វើសាក្សីឱ្យជារឿង មីចោរកញ្ចុយ មីរយាស់ ធ្វើចាស់មិនត្រឹមត្រូវ ជេរទៅ កាន់ អ ព មីការ ព មីចោរកញ្ចុយមានក្បួយប៉ុន្មាននាក់ដើរឱ្យគេចុយ ។

-សាក្សីបំភ្លឺឈ្មោះ ឃ ច បានឆ្លើយបញ្ជាក់ថា : ឈ្មោះ គ រ កន្លងមកពេលផឹកស៊ីស្រាស្រវឹងមកដល់ផ្ទះ ជេរបញ្ចោរអ្នកជិតខាង ប្រពន្ធកូនស្ទើររាល់ថ្ងៃ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៤ ម៉ោង ១១:០០យប់ គ រ ជេរប្រពន្ធ ជេរ ៩ ឆ អាចុយម្ដាយ អា ឆ បើមានហ្វេងអត់អញចេញមកកាប់គ្នា ។ គ រ ទៅជេរ ខ ឡ ទៀតមីកញ្ចាស់ មីរយាស់ ជេរទៅ អ ព មីចោរកញ្ចុយ មីចោរការ ព ហងឯងមានក្បួយប៉ុន្មាននាក់ដើរឱ្យគេចុយ ។ ខ្ញុំឆ្លើយតែការពិត ។

-សាក្សីបំភ្លឺឈ្មោះ អ ស បានឆ្លើយបញ្ជាក់ថា : ឈ្មោះ គ រ ផឹកស៊ីស្រវឹងជេរជៀមជាមអ្នកជិតខាង ប្រពន្ធកូន ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៤ វេលាម៉ោង ១១:៣០នាទីយប់ គ រ ជេរទៅ ៩ ឆ ទៅជេរទៅ ខ ឡ និងជេរទៅ អ ព មានចម្លើយដូចឈ្មោះ ម សរ និងឈ្មោះ ឃ ច បញ្ជាក់រួចហើយ ។

-របាយការណ៍លេខ ០៤ ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៤ របស់អធិការនគរបាលប៉ុស្តិ៍ឃុំកំពង់រទេះ ស្រុកស្ទឹងសែនបានបញ្ជាក់ថា នៅត្រង់បរិវេណជនល្មើសឈ្មោះ គ រ ជនល្មើសបានជេរទៅលើឈ្មោះ អ ព ។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានតាមច្បាប់ថា រក្សាបទចោទដដែល សូមតុលាការសម្រេចសេចក្ដី តាមច្បាប់ ។

-បានស្ដាប់ចម្លើយជនជាប់ចោទ

-បានស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

-បានស្ដាប់ចម្លើយសាក្សី

-បានស្ដាប់ចម្លើយសេចក្ដីសន្និដ្ឋានទោសរបស់តំណាងអយ្យការ



Scanned with CamScanner

**តុលាការខេត្តកំពង់ធំ**

បានពិនិត្យសំណុំរឿងចប់សព្វគ្រប់

**យល់ឃើញថា**

-យល់ឃើញថា : ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៤ វេលាម៉ោង ១២:៣០នាទីយប់ ឈ្មោះ គ រ មកពីផឹកស្រាស្រវឹងបានជេរប្រមាថលើឈ្មោះ អ ព ដែលកំពុងដេកនៅលើផ្ទះ ។

-យល់ឃើញថា : ឈ្មោះ គ រ ពេលបានផឹកស៊ីស្រែកជេរជៀមដាមទាំងយប់ដោយគ្មានមូលហេតុ ។

-យលឃើញថា : ឈ្មោះ គ រ បានជេរប្រមាថទៅលើឈ្មោះ អ ព ធ្វើឱ្យខូចខាតបង់កិត្តិយស និងសេចក្ដីថ្លៃថ្នូរដល់អ្នករងគ្រោះ ព្រមទាំងបរិហាកេរ្ដិ៍គាត់ថែមទៀតផង ។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា : រក្សាបទចោទដដែល សូមតុលាការសម្រេចផ្ដន្ទាទោសទៅតាមច្បាប់ ។

-ដើមបណ្ដឹងរដ្ឋប្បវេណី សុំឱ្យតុលាការផ្ដន្ទាទោសជនល្មើសទៅតាមច្បាប់ ទាមទារជម្ងឺចិត្តជាប្រាក់ ២លានរៀល តុលាការពិចារណា ។

-ឈ្មោះ គ រ ល្មើសនឹងមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

**ហេតុដូច្នេះតុលាការខេត្តកំពង់ធំ**

**វិនិច្ឆ័យសេចក្ដី**

១-ផ្ដន្ទាទោសឈ្មោះ គ រ ភេទប្រុស អាយុ ៣៦ឆ្នាំ ដាក់ពន្ធនាគារ ចំនួន ០២ខែ តែទោសនេះត្រូវព្យួររយៈពេលសាកល្បង ០៥ឆ្នាំ ។ ពីបទ : ជេរប្រមាថ ប្រព្រឹត្តនៅភូមិកំពង់រទេះ ឃុំកំពង់រទេះ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៤ ។ បទល្មើសដែលមានចែងឱ្យផ្ដន្ទាទោស តាមមាត្រា ៦៣, ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ទោសខាងលើនេះគិតតាំងពីសាលក្រមមានអនុភាពអនុវត្តចូលជាស្ថាពរតទៅ ។

២-សម្រេចពិន័យលើឈ្មោះ គ រ ជូសជុលជម្ងឺចិត្តជាប្រាក់ ០៣ម៉ឺនរៀល ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ ។

៣-អោយឈ្មោះ គ រ ជូសជុលជម្ងឺចិត្តជាប្រាក់ ២០ម៉ឺនរៀល ឱ្យទៅដើមបណ្ដឹងរដ្ឋប្បវេណី ឈ្មោះ អ ព បណ្ដឹងលើសពីនេះត្រូវលើកចោល ។ បើឈ្មោះ គ រ មិនមានប្រាក់បង់ទេបង្ខំរូបកាយដាក់គុកទារប្រាក់ធនទណ្ឌ ។

៤-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្ដីទុកសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ចៅក្រមជំនុំជំរះ**

**ហត្ថលេខា និងត្រា** [redacted]

**បានឃើញ**

**ចៅក្រមជំនុំជំរះតុលាការខេត្តកំពង់ធំ**

[redacted]



Scanned with CamScanner